១២	**ខៀវ ឈុនលី**	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧

១៣	ឆន់ សុគន្ធនារី	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៤	ស៊ិន ឆុន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៥	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៥	អ៊ី សាងលី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៦	ប៉ុល សុរិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៧	នុត សុផន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៨	ធីវ សុខុម	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
១៩	ហាក់ សាំងសួរ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២០	ឌីវ សាន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២១	ស៊ីវ សេដ្ឋា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២២	លឿង ស៊ីវ៉ាត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២៣	ហ៊ិន ម៉េងស្រី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២៤	ឈុំ ឆុនលី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៧
២៥	ឈុន ហុត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
២៦	ចាន់ ខេង	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
២៧	ស៊ីវ ធួន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ៨
២៨	អៀ ចាន់ណារី	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨

p

២៩	សេក សុខា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣០	សួន យ៉េន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣១	តុល នរិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣២	សួស ម៉ន	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣៣	លី សុធឿន	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣៤	តាក ហាប់	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣៥	ឌី សុខន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣៦	ឈុន សុផល	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៧	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៨
៣៧	ពុត សាមិត្ត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៣៨	ប៉ៅ សំអាន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៣៩	អ៊ឹម ម៉ៅហុក	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤០	ឡោ ធវណ្ណា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤១	មាស វណ្ណា	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤២	ប៊ី គឹមសែន	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៣	ហេង សាគីម	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៤	សុខ សំអឿន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩

៤៥	មាស តិរុណា	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៦	ណុប សៀងហោ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៧	សេង គឹមហេង	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៨	មាស ស៊ិត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៤៩	គីម សុនថន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
៥០	ទ៉ា ឆុន្នី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥១	ញេប ពិដោរ	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥២	ឆា គន់	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥៣	ជុនហៀង ថាវរិទ្ធិ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ១០
៥៤	សៀងឯម ឧនឹម	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ១០
៥៥	ជា សឿន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥៦	សំ ទ៉ា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥៧	ឌី បុណ្ណា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥៨	លាង ឆេងហួយ	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥៩	ហ៊ិត ស៊ីរោត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦០	ឈុន ថាណា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០

p

៦១	ញាន សារឿន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦២	ខៀច សំអុល	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៣	សុខ ស៊ីដេត	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៤	គួច គួលំអ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៥	ទេន សំអុនសុន្ទរី	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៦	ជា ខុង	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៧	ម៉ុន ជានស៊ីផល	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៨	តេង សុភាលក្ស៊ី	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៦៩	យស់ ផល្លី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧០	យឹម សំណាង	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧១	ផាន់ស៊ុន ធាវី	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧២	ហេង ផេង	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៣	អ៊ីង សាង	ស	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៤	ចាន់ សុភា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៥	ទូច វិសាលសុខ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៦	ប៊ិន ធុំ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០

p

៧៧	**អ៊ុក ឧត្តរៈ**	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៨	**សិត ខន**	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៧៩	**គួច ភាព**	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ១៤១ [illegible] ប្រក

លិខិតចូល

ថ្ងៃទី.......ខែ.......ឆ្នាំ20...

ប្រកាស

ស្តីពី

នីតិវិធី និងបែបបទនៃការស្នើសុំលិខិតអនុញ្ញាត ការនាំចូលឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៥៨ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣២៤ ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ស្តីពី ការអនុវត្តច្បាប់មាត្រាសាស្ត្រកម្ពុជា
- បានឃើញសេចក្តីជូនដំណឹងលេខ ០៣៨ ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ស្តីពីការនាំចូលឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រ
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១.- ប្រកាសនេះមានគោលដៅកំណត់ យន្តការ និងបែបបទគ្រប់គ្រងការនាំចូលឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទ និងស្តង់ដារមាត្រាសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣

ប្រការ ២.- ប្រកាសនេះមានគោលបំណង:

- ធានាឲ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម មានភាពយុត្តិធម៌ និងត្រឹមត្រូវ
- បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ ស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់
- ធ្វើឲ្យមានជំនឿ និងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន ។

ប្រការ ៣.- ប្រកាសនេះ មានវិសាលភាពអនុវត្តលើបុគ្គលដែលនាំចូលឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និងស្តង់ដារមាត្រាសាស្ត្រ សម្រាប់សកម្មភាពធ្វើពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម កាន់កាប់ ប្រើប្រាស់ ធ្វើអាជីវកម្ម និង/ ឬ វិស័យផ្សេងទៀត ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤.- វាក្យស័ព្ទសំខាន់ៗ ប្រើសម្រាប់ក្នុងប្រកាសនេះ មានដូចតទៅ:

ឧបករណ៍មាត្រាសាស្ត្រ សំដៅដល់ ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបម្រើឲ្យវិស័យមាត្រាសាស្ត្រ ។

ស្តង់ដារមាត្រាសាស្ត្រ សំដៅដល់ ឧបករណ៍ខ្នាតគំរូមាត្រាសាស្ត្រ ។

ពាណិជ្ជកម្ម សំដៅដល់ ទំនាក់ទំនង ឬ កិច្ចសន្យា កិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា និងរាប់បញ្ចូលទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការអនុម័តគំរូ សំដៅដល់ ការអនុម័តលើគំរូជាកលាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រ សម្រាប់ដាក់ឲ្យប្រើប្រាស់បន្ទាប់ពីបានសាកល្បងឧបករណ៍មួយ ឬច្រើនស្របតាមការតម្រូវដែលបានកំណត់ ។

ពាណិជ្ជសញ្ញា សំដៅដល់ ម៉ាកដែលប្រើប្រាស់សម្រាប់សេវា ហៅថាសេវាសញ្ញាមាត្រាសាស្ត្រ ។

អ្នកស្នើសុំ សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើពាក្យស្នើសុំលិខិតអនុញ្ញាត ដោយអនុលោមតាមប្រកាសនេះ ។

អ្នកនាំចូល សំដៅដល បុគ្គលដែលបានអនុញ្ញាតឲ្យនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ និង/ ឬ ស្តង់ដារមាត្រាសាស្ត្រ ។

បុគ្គល សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល ។

ពាក្យស្នើសុំ សំដៅដល់ ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ ជាសំណើផ្លូវការដោយលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ ដើម្បីទទួលបាននូវសិទ្ធិលើការនាំចូលឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និង/ ឬ ស្តង់ដារមាត្រាសាស្ត្រ ដូចមានទម្រង់ដែលកំណត់ ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

លិខិតអនុញ្ញាត សំដៅដល់ លិខិតគតិយុត្តដែលអនុញ្ញាតឲ្យបុគ្គលធ្វើសកម្មភាព ឬ មានបំណងធ្វើសកម្មភាពនាំចូលឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និង/ ឬ ស្តង់ដារមាត្រាសាស្ត្រ ជា

p

ហើយលាយលក្ខណ៍អក្សរដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាពរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ ពីថ្ងៃចុះហត្ថលេខា ។

ឯកសារតម្រូវ សំដៅដល់ ឯកសារពាក់ព័ន្ធនានាដែលតម្រូវឲ្យមានភាពអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ ។

មន្ត្រីត្រួតពិនិត្យ សំដៅដល់ មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា ។

មន្ត្រីមានសមត្ថកិច្ច សំដៅដល់ មន្ត្រីរាជការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

នាយកដ្ឋានទទួលបន្ទុក សំដៅដល់ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

រដ្ឋមន្ត្រី សំដៅដល់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ រាល់ឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និងស្តង់ដារមាត្រាសាស្ត្រ អាចអនុញ្ញាតឲ្យនាំចូលសម្រាប់កាន់កាប់ ប្រើប្រាស់ក្នុងការធ្វើ សកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ឧស្សាហកម្ម និង/ឬ វិស័យផ្សេងៗទៀតដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតការនាំចូលឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ ឲ្យបានត្រឹមត្រូវពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦.- បុគ្គលធ្វើសកម្មភាព ឬ មានបំណងធ្វើសកម្មភាពនាំចូលរាល់ឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និងស្តង់ដារមាត្រាសាស្ត្រ ត្រូវមកដាក់ពាក្យស្នើសុំនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ រៀងរាល់ថ្ងៃធ្វើការ ។

ពាក្យស្នើសុំ ត្រូវមានភ្ជាប់មកជាមួយនូវលក្ខខណ្ឌដូចខាងក្រោម៖

ក. ពាក្យស្នើសុំលិខិតអនុញ្ញាត (មានបិទតែម ៥០០ រៀល)

ខ. កិច្ចសន្យា ស្តីពី ការសុំនាំចូលឧបករណ៍មាត្រាសាស្ត្រ និង/ឬ ស្តង់ដារមាត្រាសាស្ត្រ

គ. បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រ និង/ឬ ស្តង់ដារមាត្រាសាស្ត្រ ដែលបំរុងធ្វើការនាំចូល

ឃ. វិញ្ញាបនប័ត្រចុះបញ្ជីមាត្រាសាស្ត្រ (ច្បាប់ចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម)

ង. វិញ្ញាបនប័ត្រអនុម័តគំរូ (ច្បាប់ចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម) ។

ប្រការ ៧.- ពាក្យស្នើសុំអាចទទួលបាន បន្ទាប់ពីនាយកដ្ឋានទទួលបន្ទុកពិនិត្យឃើញថា អ្នកស្នើសុំបានបំពេញនូវពាក្យស្នើសុំលិខិតអនុញ្ញាត និងឯកសារតម្រូវ ត្រឹមត្រូវ និងច្បាស់លាស់ តាមប្រការ៦ នៃប្រកាសនេះ ។ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ពិនិត្យវាយតម្លៃដោយអនុលោមតាមលក្ខខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យមាត្រាសាស្ត្រ រួចដាក់ជូនរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច ។ លិខិតអនុញ្ញាតអាចផ្តល់ជូនក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ យ៉ាងយូរ ដោយគិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ ។

ប្រការ ៨ លិខិតអនុញ្ញាតមិនអាចផ្ទេរ ឬ លក់ ឲ្យទៅបុគ្គលផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ការបញ្ឈប់ ការផ្អាក ការពន្យារពេលមិនធ្វើការនាំចូល ត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុឲ្យបានត្រឹមត្រូវ ច្បាស់លាស់ ព្រមទាំងភ្ជាប់នូវលិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធនានាជូនមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ឲ្យបាន ៣០ (សាមសិប) ថ្ងៃ មុនលិខិតអនុញ្ញាតផុតសុពលភាព ។

ប្រការ ៩ ករណីការនាំចូលច្រើនជាងបរិមាណ ឬ ផុតសុពលភាពនៃលិខិតអនុញ្ញាត ហើយនៅតែធ្វើសកម្មភាពនាំចូលបន្ត អ្នកនាំចូលត្រូវមកដាក់ពាក្យស្នើសុំសារជាថ្មី ដូចប្រការ៦ និងប្រការ៧ នៃប្រកាសនេះ ។

ប្រការ ១០.- នៅពេលឧបករណ៍មាត្រាសាស្ត្រ និង/ឬ ស្តង់ដារមាត្រាសាស្ត្រ បាននាំចូលមកដល់កម្ពុជា (ទីកន្លែងស្តុក) អ្នកនាំចូលត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីស្នើសុំមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យអង្កេតជាក់ស្តែង ។

ប្រការ ១១.- លក្ខខណ្ឌនៃឧបករណ៍មាត្រាសាស្ត្រ និងស្តង់ដារមាត្រាសាស្ត្រ ត្រូវបានអនុញ្ញាតឲ្យនាំចូលលុះត្រាតែ:

- មានភាពត្រឹមត្រូវ និងសមមូល ឬស្របទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុង **ឧបសម្ព័ន្ធទី១** និង **ឧបសម្ព័ន្ធទី២** នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា មានការបញ្ជាក់សមត្ថភាព អប្បបរមា និងអតិបរមា អំពីទម្ងន់ និង/ឬ ង្វាស់ង្វាល់នៃឧបករណ៍មាត្រាសាស្ត្រនោះ
- ត្រូវមានពាណិជ្ជនាម ឬ អាសយដ្ឋានផលិតច្បាស់លាស់ ។

ប្រការ ១២. ករណីមិនបានអនុវត្តតាមប្រការ១០ ឬ ប្រការ១១ នៃប្រកាសនេះ អ្នកនាំចូលមិនអាចធ្វើសកម្មភាពក្នុងការផ្គត់ផ្គង់ ចែកចាយ ផ្ទេរ លក់ ជួល ប្រើប្រាស់ ឬ បញ្ចេញពីទីកន្លែងស្តុកបានឡើយ ។

ប្រការ ១៣.- បុគ្គលកំពុងធ្វើសកម្មភាពនាំចូលរាល់ឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ និង/ ឬ ស្តង់ដារមាត្រាសាស្ត្រ ត្រូវមកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ដើម្បីទទួលសិទ្ធិធ្វើសកម្មភាពបន្តការនាំចូលក្នុងរយៈពេលមិនលើស ពី ៣ (បី) ខែ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ព្រមទាំងបុគ្គលដែលបាននាំចូលរួច ហើយកាន់កាប ដើម្បីប្រើប្រាស ជួល ចែកចាយ លក់ ឬ ដាក់តាំងសម្រាប់លក់នៃឧបករណ៍មាត្រាសាស្ត្រ ត្រូវមកបំពេញសំណុំបែបបទ ដើម្បីសុំការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង ដោយមន្ត្រីមានសមត្ថកិច្ចក្នុងរយៈពេល មិនលើស ពី ៣ (បី) ខែ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បន្ទាប់ពីប្រកាសនេះ ចូលជាធរមាន ។

ប្រការ ១៤. ករណីមិនបានអនុវត្តតាមប្រការ៨ ឬ ប្រការ១២ នៃប្រកាសនេះ អ្នកនាំចូលត្រូវទទួលការព្រមាន ។

ករណីអ្នកនាំចូលមិនរាងចាលនៅតែប្រព្រឹត្ត មិនគោរពបទប្បញ្ញត្តិខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិដកហូតលិខិតអនុញ្ញាតដោយមិនមានកំណត់ ឬ មិនផ្តល់លិខិតអនុញ្ញាតថ្មី ឬ បញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។

p

ប្រការ ១៥ ករណីមិនបានអនុវត្តតាមប្រការ៥ ឬ ប្រការ១១ ឬ ប្រការ១៣ នៃប្រកាសនេះ បុគ្គលដែលនាំចូលត្រូវទទួលការព្រមាន និងពិន័យអន្តរការណ៍ ដូចមានចែងក្នុងជំពូកទី១០ "ទោសប្បញ្ញត្តិ" នៃច្បាប ស្តីពី មាត្រាសាស្ត្រកម្ពុជា ។

ប្រការ ១៦.- ការព្រមាន និងពិន័យអន្តរការណ៍ដែលមានចែងក្នុងប្រកាសនេះ ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

ករណីជនល្មើស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ និងករណីរឹបអូសទំនិញ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។

ប្រការ ១៧.- រាល់ប្រកាស. និងសេចក្តីសម្រេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៨.- អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ១៩.- ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២

រដ្ឋមន្ត្រី

ស៊ុយ សែម

កន្លែងទទួលៈ
ទីស្តីការគណៈរដ្ឋមន្ត្រី
ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងមហាផ្ទៃ
ក្រសួងពាណិជ្ជកម្ម
គ្រប់ក្រសួង - ស្ថាប័នជំនាញពាក់ព័ន្ធ
អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
សភាពាណិជ្ជកម្មកម្ពុជា
គ្រប់សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"

គ្រប់នាយកដ្ឋានសេនាធិការ និងថ្នាក់ស្មើ ក្រសួងឧរថ
គ្រប់សហគ្រាសសាធារណៈចំណុះក្រសួងឧរថ
មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី - ខេត្ត
"ដើម្បីសហការអនុវត្ត"
ដូចប្រការ ១៨ "ដើម្បីអនុវត្ត"
ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៣.៧៩ ឧ.ស.ក-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២២៣១/១១ គ.វ.កចុះថ្ងៃទី២០.០៩.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ចុះថ្ងៃទី០៨.០៩.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ថុង ឆាវ អេនធើប្រាយ (ខេមបូឌា) (TUNG CHAO ENTERPRISE (CAMBODIA) LTD.) តំណាងដោយ លោកស្រី CHANG, LI-YING សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 301442061 ចុះថ្ងៃទី១៦.០៨.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ 5F, No.10, Ln-68, Qiangang St., Shilin Dist., Taipei City 111, Taiwan, R.O.C. ជាម្ចាស់រោងចក្រធ្វើការ បង្កើតរោងចក្រ លើផលិតផលខាង ក្រោម:

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់សកម្មភាពឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh, Phnom Penh, Phone 855-23-211141 , Fax . 855-23 428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ចុង ឆាវ អេនធើប្រាយ (ខេមបូឌា) "*

ទីតាំងរោងចក្រ ៖ *"ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចចូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/តាមផ្ទុ

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ពេលវេលា អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចបានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន.
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនព្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ ៣៩០ ឧ.ថ.-ក.ឱ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៨២ /១២ គ.វ.ក ចុះថ្ងៃទី២៦.០១.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដាគាន ថេកស្ថាយ (ខេមបូឌា) ចុះថ្ងៃទី៣០.១២.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ដាគាន ថេកស្ថាយ (ខេមបូឌា) (DAQIAN TEXTILE (CAMBODIA) CO.,LTD.) . តំណាងដោយលោក HUANG GUANLIN សញ្ជាតិចិន អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G25507053 ចុះថ្ងៃទី២៦.១០.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ Unit 301, Building 8,Liren Garden Beilun District,Ningbo,Zhejiang Province.ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់តាម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh Phnom Penh Phone 855 23 211141 Fax 855 23 428263

- **ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រកាត់ដេរ សម្លៀកបំពាក់ ដាគួាន ថេកស្តាយ (ខេមបូឌា)* "

ទីតាំងរោងចក្រ ៖ " *ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ* "

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចចូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាបន្តបន្ទាប់គ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ពេលវេលា អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ភ្នំពេញ ថ្ងៃទី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងបរិស្ថាន
ក្រសួងពាណិជ្ជកម្ម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
ដូចប្រការ១៤ "ដើម្បីអនុវត្ត"
ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry Mines and Energy

លេខ . ៣៥៨៥ ឧ.រ.ថ.គង .ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ២៣៧១ /១១ គ.វ.ក ចុះថ្ងៃទី១១.១០.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ធី & ខេ ហ្គាមេន អ៊ិនដាស្ទ្រី ចុះថ្ងៃទី១៨.១១.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ធី & ខេ ហ្គាមេន អ៊ិនដាស្ទ្រី (T & K GARMENT INDUSTRY CO.,LTD.) តំណាងដោយលោក XU ZONGWU សញ្ជាតិចិន អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G35983489 ចុះថ្ងៃទី២៨.១១ ២០០៥ មានទីលំនៅបច្ចុប្បន្ន: No 2, Bei Lei village, Binhu District, Wuxi,Jiangsu Province, China ជាម្ចាស់រោងចក្រធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev 4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១១១៤១ ទូរសារ : ៨៥៥ ២៣ ៤២៨២៦៣
45 ... Norodom Blvd ... Khan Daun Penh, Phnom Penh ... 855 23 211141 ... 855 23 428...

- **ផ្លាកឈ្មោះរោងចក្រ** ៖ " *រោងចក្រកាត់ដេរសម្លៀកបំពាក់ ធី & ខេ ហ្គាមេន អ៊ិនដាស្ទ្រី "សាខាទី១"* "
- **ទីតាំងសាខារោងចក្រ** ៖ " *អាគារ F ផ្លូវបេាមពៅ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ* "

ប្រការ២. ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់តម្លៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ កុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងរយៈពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងរយៈពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះល្បើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

កន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៣៩៩៩ ឧ.ម.ថ-កន-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២២២/១២ គ.វ.ក ចុះថ្ងៃទី០៦.០២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យ៉ាំង អ៊ិននើរ (ខេមបូឌា) ចុះថ្ងៃទី២០.១២.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន យ៉ាំង អ៊ិននើរ (ខេមបូឌា) (YOUNG INNER (CAMBODIA)CO., LTD.) តំណាងដោយលោក JOUNGDUK LEE សញ្ជាតិកូរ៉េ អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M68055515 ចុះថ្ងៃទី១២.០៥.២០១០មានអាសយដ្ឋានបច្ចុប្បន្ន 230-54 Gugi dong, Jongno gu, Seoul, Korea ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រផលិតផលសំលៀកបំពាក់ ដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone 855 23-211141 Fax 855 23 428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ យ៉ោង ស៊ិនធើរ (ខេមបូឌា) "*
ទីតាំងរោងចក្រ ៖ *" ភូមិជើងឯក សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។/.

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖
